ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

90/10

## តាមនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ២៨
ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២
សាលដីកា
លេខ: ២៦
ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោកស្រី [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោកស្រី [redacted] ជាចៅក្រម

ក្រឡាបញ្ជី
លោកស្រី [redacted]

តំណាងមហាអយ្យការ
ឯកឧត្តម [redacted]ចាន់ថា អគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ១០៤ក្រIII"ឃ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២៨ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់តុលាការកំពូល។

ពីបទ: អូសទាញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

-ជនជាប់ចោទ៖

១-ឈ្មោះ[redacted]ផាង (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិវាំងខាងត្បូង ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ មុខរបរ លក់ត្រី ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ៦១២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ[redacted]ន "រ" ប្តីឈ្មោ[redacted]មានកូន៤នាក់ ទោសពីមុនគ្មាន។ ឃាត់ខ្លួនថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០។ (ព្រៃសម២)



Scanned by CamScanner

២-ឈ្មោះ [redacted] ពៅ (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិជីឃ្មល់ ឃុំគោកព្រិច ស្រុកគីរីវង្ស ខេត្តតាកែវ មុខរបរ តួកជេដី ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ១១$E_1$ ផ្លូវ៣២២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "រ" ប្តីឈ្មោះ [redacted] មានកូ១នាក់ ទោសពីមុនគ្មាន។ ឃាត់ខ្លួនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០, ឃុំខ្លួនថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០។ (ព្រៃសម₂)

-មានមេធាវី លោក [redacted] សុផល និងលោក អ៊ឹម ម៉ាច

៣-ឈ្មោ[redacted]ធី (ជាម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ-ឃុំពាលញែក ស្រុកបាកាន ខេត្តពោធិ៍សាត់ ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ៣៥ ផ្លូវ១៦៥ សង្កាត់អូរឬស្សី ខណ្ឌ៧មករា រាជធានីភ្នំពេញ ឪពុកឈ្មោ[redacted]រ" ម្តាយឈ្មោ[redacted]"ស" ប្តីឈ្មោះ [redacted] "លែងលះ" មានកូន៣នាក់ ទោសពីមុនគ្មាន។ ឃាត់ខ្លួនថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០,ឃុំខ្លួនថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០។ (ព្រៃសម₆)

-មានមេធាវីលោក[redacted] ឡុង

៤-ឈ្មោះ [redacted] ធីហៀង ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិវៀតណាម កើតនៅប្រទេសវៀតណាម មុខរបរ កោសខ្យល់ ទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ០៣ ផ្លូវK៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ[redacted] "រ" ប្តីឈ្មោះ [redacted] "ស" មានកូន១នាក់ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០។ (ក្រៅឃុំ)

៥-ឈ្មោះ [redacted] អេះ ភេទស្រី អាយុ៥៩ឆ្នាំ ជនជាតិវៀតណាម កើតនៅស្រុកព្រែកជ្រូក ប្រទេសវៀតណាម មុខរបរ លក់ផ្លែដូងខ្ចី ទីលំនៅមុនពេលឃាត់ខ្លួន ផ្ទះលេខ២៤ ភូមិទាពាំងអញ្ចាញ សង្កាត់ត្រពាំងក្រសាំង សង្កាត់ដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្តីឈ្មោះ [redacted]មានកូន៥នាក់ ទោសពីមុនគ្មាន។ ឃុំខ្លួនថ្ងៃទី០២ ខែមីនា ឆ្នាំ២០១០។ (ក្រៅឃុំ)

-ជនរងគ្រោះឈ្មោះ [redacted] ពៅ ភេទស្រី អាយុ១៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ១៩A ផ្លូវ១៤៥ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] "រ" ម្តាយឈ្មោះ [redacted]រ"។

-ជនរងគ្រោះឈ្មោះ [redacted] ធីទៀកម៉ាយ ភេទស្រី អាយុ១៥ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃផ្ទះលេខ០៣ ផ្លូវK៥ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] ធីហៀង "រ"។

-មានមេធាវីលោ[redacted]រឿន...



156

Scanned by CamScanner

-កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានចុះអនុវត្តតាមចំណារលេខ៦៨ អ.យ.ឃ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០ របស់ព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ បានចុះបង្ក្រាបករណីជួញដូរមួយនៅរាជធានីភ្នំពេញ ដែលកំពុងអូសទាញជនរងគ្រោះដែលឈ្មោះ [redacted] ធីទៀកម៉ាយ និងឈ្មោះ [redacted] ពៅ ដែលជាអនីតិជនអាយុក្រោយ១៨ឆ្នាំ ទៅធ្វើពេស្យាចារ ហើយកម្លាំងសមត្ថកិច្ចបានធ្វើការបង្ក្រាបជាក់ស្តែង និងឃាត់ខ្លួនជនល្មើសចំនួន ០៥នាក់ មាន១-ឈ្មោះ [redacted] ពៅ, ២-ឈ្មោះ [redacted] ធី, ៣ [redacted] អេះ, ៤-ឈ្មោះ [redacted] ផាង និងឈ្មោះ [redacted] ធីហៀង មកកាន់ការិយាល័យតែម្តង។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញថាៈ តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ពៅ, ឈ្មោះ [redacted] ធី, ឈ្មោះ [redacted] ផាង, ឈ្មោះ [redacted] អេះ និងឈ្មោះ [redacted] ធីហៀង និងជនរងគ្រោះឈ្មោះ [redacted] ពៅ និងឈ្មោះ [redacted] ធីទៀកម៉ាយ បញ្ជាក់ថាជនជាប់ចោទទាំងប្រាំនាក់ ពិតជាបានរួមគំនិតគ្នារកម៉ូយមកទិញជនរងគ្រោះទាំងពីរនាក់មែន។ អំពើរបស់ជនជាប់ចោទទាំងប្រាំនាក់នេះ ជាបទល្មើស អូសទាញពេស្យាចារកុមារ ដែលមានចែងក្នុងមាត្រា ៣៥ នៃច្បាប់ស្តីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ សូមតម្កល់ការចោទប្រកាន់ ដូចក្នុងដីកាសន្និដ្ឋានស្ពាពរទាំងស្រុង។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចៈ

១-ផ្តន្ទាទោសៈ

ក-ឈ្មោះ [redacted] ផាង ភេទស្រី អាយុ៤០ឆ្នាំ ជាតិខ្មែរ

ខ-ឈ្មោះ [redacted] ធី ភេទស្រី អាយុ៤៣ឆ្នាំ ជាតិខ្មែរ

គ-ឈ្មោះ [redacted] ពៅ ភេទស្រី អាយុ៥១ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល៧ឆ្នាំ (ប្រាំពីរឆ្នាំ)

ឃ-ឈ្មោះ [redacted] ធីហៀង ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិវៀតណាម

ង-ឈ្មោះ [redacted] អេះ ភេទស្រី អាយុ៥៩ឆ្នាំ ជនជាតិវៀតណាម

ដាកពន្ធនាគារកំណត់ក្នុងម្នាក់ៗ កំណត់រយៈពេល៣ឆ្នាំ (បីឆ្នាំ) និងពិន័យជាប្រាក់ក្នុងម្នាក់ៗចំនួន ៤.០០០.០០០រៀល (បួនលានរៀល) ពីបទៈ អូសទាញពេស្យាចារកុមារ ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០, តាមមាត្រា៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

២-លើកចោលការទាមទាររបស់មេធាវី [redacted] ារឿន របស់ជនរងគ្រោះឈ្មោះ សឹង ពៅ។

៣-វត្ថុតាងៈ

ក-ទូរស័ព្ទដៃម៉ាកណូគា ចំនួន០៣គ្រឿង ដូចក្នុងកំណត់ហេតុទទួលវត្ថុតាង លេខ០៩៩ អ.យ.ញ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១០ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ។

ខ-សៀវភៅកត់លេខទូរស័ព្ទចំនួន៣ក្បាល ត្រូវរឹបអូសបំផ្លាញចោល។

៤-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ,ជនរងគ្រោះ, មេធាវីការពារជនរងគ្រោះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ ជនរងគ្រោះ, មេធាវីការពារជនរងគ្រោះ។ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៨៤៥ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោ[redacted]ពៅ និងបណ្តឹងឧទ្ធរណ៍លេខ៨៥៩ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោះ[redacted]ធី ,បណ្តឹងឧទ្ធរណ៍លេខ៨៦១ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ឈ្មោ[redacted]ផាង ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃដីកាសម្រេចទាំងមូល និងបណ្តឹងឧទ្ធរណ៍លេខ៩០០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ របស់ឈ្មោះ[redacted]សារឿន ជាមេធាវីទទួលសិទ្ធិពីឈ្មោះ[redacted]ឌីក ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសំណងរដ្ឋប្បវេណី។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: សាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ បានសម្រេចសេចក្តីត្រឹមត្រូវហើយ មហាអយ្យការសូមសភាព្រហ្មទណ្ឌ តម្កល់ទុកជាបានការដដែល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ១០៤"ក្រ.III.ឃ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចៈ

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍លេខ៨៤៥ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោ[redacted]ពៅ, បណ្តឹងឧទ្ធរណ៍លេខ៨៥៩ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ [redacted] ធី,បណ្តឹងលេខ៨៦១ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១០ របស់ជនជាប់ចោទឈ្មោះ[redacted] ផាង និងបណ្តឹងឧទ្ធរណ៍លេខ៩០០ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១០ របស់លោ[redacted] សារឿន ជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ឌីក ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ១២៨ក្រ១ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។



Scanned by CamScanner

៤-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១១, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ ជនជាប់ចោទ, មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងជនរងគ្រោះ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ របស់ឈ្មោ[redacted]រៀង មេធាវីការពារឱ្យឈ្មោះ[redacted] ធី និងបណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ[redacted] ពៅ ,បណ្តឹងសាទុក្ខលេខ១១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ផាង ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ១០៤"ក្រ.III.ឃ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាខេត្តរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល និងបណ្តឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ របស់លោក សេក សារឿន មេធាវីការពារឱ្យឈ្មោះ [redacted] ឌីក ប្តឹង មិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ១០៤"ក្រ.III.ឃ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាខេត្តរណ៍ ត្រង់ចំណុចសំណងរដ្ឋប្បវេណី។

-បានឃើញសារណាការបារចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោ[redacted]ពៅ។

-បានឃើញសារណាចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោ[redacted] ធី។

-បានឃើញសារណាចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ផាង។

-បានឃើញសារណាចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ឈ្មោះ[redacted] ឌីក។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: មានសាក្សី និងភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ជនជាប់ចោទខាងលើពិតជា បានប្រព្រឹត្តបទអូសទាញពេស្យាចារកុមារ។ ចម្លើយដោះសាររបស់ជនជាប់ចោទខាងលើ មិនអាចគួរឱ្យជឿជាក់បានទេ។ ជនជាប់ចោទជាពិតិជន និងមានស្មារតីល្អធម្មតា គឺមានសមត្ថភាពគ្រប់គ្រាន់ទទួលខុសត្រូវរាល់ទង្វើរបស់ខ្លួន ដែលបានប្រព្រឹត្ត។ មានធាតុផ្សំគ្រប់គ្រាន់ដែលបញ្ជាក់ថា ជនជាប់ចោទខាងលើពិតជាបានរួមគ្នាប្រព្រឹត្តបទអូសទាញពេស្យាចារកុមារ គឺជាបទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៥ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។

ដើម្បីជាផលប្រយោជន៍ច្បាប់ ផលប្រយោជន៍ជនរងគ្រោះ និងយុត្តិធម៌ មហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះ សម្រេច:

-តម្កល់សាលដីការបស់សភាព្រហ្មទណ្ឌ នៃសាលាខេត្តរណ៍ ទុកជាបានការពេញទាំងមូល។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted]ផាង នាពេលសវនាការថា៖ ខ្ញុំមិនសុខចិត្ត ព្រោះខ្ញុំមិនបានធ្វើ កូនស្រីឈ្មោ[redacted]ធីទៀកម៉ាយ គាត់ស៊ីឈ្នួលកោស



159

Scanned by CamScanner

ប្រហិតឱ្យខ្ញុំ ម្តាយកូនស្រីឈ្មោះ[redacted] ធីហៀង គាត់យកមកឱ្យស៊ីឈ្នួលកោសប្រហិតឱ្យនាងខ្ញុំ។ 90/5
ឈ្មោះ[redacted] ធីហៀង ជាម្តាយក្មេងស្រី គាត់ស្គាល់ខ្ញុំ បានផ្ញើរកូនមកស៊ីឈ្នួលកោសប្រហិតត្រីឱ្យខ្ញុំក្នុងមួយខែ៤០ ដុល្លារ ព្រោះខ្ញុំកោសប្រហិតក្នុង១ថ្ងៃ គឺបាន១០០គីឡូ។

ពេលថ្ងៃកើតហេតុ នាងខ្ញុំលក់ប្រហិតនៅផ្សារ ចំពោះក្មេងស្រីទៀកម៉ាយ នៅផ្ទះកោសប្រហិត។ ពេលមកដល់ផ្ទះខ្ញុំសួរកូនខ្ញុំថា ធីទៀកម៉ាយទៅណា? កូន១ថា ទៅផ្ទះម្តាយវាបាត់ហើយ ពេលនោះម៉ូតូឌុបមកប្រាប់ថា មានក្មេងគ្រោះថ្នាក់ចរាចរ ខ្ញុំក៏ទៅដល់ខណ្ឌ ក៏គេប្រាប់ខ្ញុំថា ឱ្យទៅហៅម្តាយមកប្រយ័ត្នគេថាជួញដូរ ពេលនោះខ្ញុំក៏ទៅហៅម្តាយកូនស្រីនោះ មករកកូន។ ខ្ញុំស្គាល់ម្តាយក្មេងស្រីឈ្មោះ[redacted]ធីហៀង រាប់អានគ្នាធម្មតា។ ខ្ញុំមានមុខរបរ កោសប្រហិតតាំងពីអាយុ២០ឆ្នាំ។ ខ្ញុំសូមស្បថមិនបានប្រព្រឹត្ត និងការអូសទាញពេស្យាចារកុមារនោះទេ។

<u>សំណូមពរ:</u> សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាជួយដោះលែងនាងខ្ញុំ ឱ្យមានសេរីភាពឡើងវិញ ដើម្បីឱ្យខ្ញុំបានទៅចិញ្ចឹមកូនវិញផង។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted] នាពេលសវនាការថា៖ ខ្ញុំមិនសុខចិត្ត ព្រោះនាងខ្ញុំមិនបានប្រព្រឹត្តបទល្មើស ដូចពាក្យដែលបានចោទប្រកាន់នោះទេ ខ្ញុំជាអ្នករកស៊ីគប់ដេដី សមត្ថកិច្ចបានហៅខ្ញុំសួរស្គាល់[redacted] ផាង គាត់ជាអ្នកលក់ប្រហិតស្រីនៅផ្សារដេប៉ូ ខ្ញុំជាអ្នកដើរផ្សារទិញម្ហូបរាល់ថ្ងៃ ហើយស្គាល់គាត់ជាលក្ខណៈអ្នកលក់ និងអ្នកទិញ តែប៉ុណ្ណោះ។

ចំណែកឈ្មោះ[redacted] ពៅ ព្រោះគាត់រកស៊ីគប់ដេដី និងផ្ទះ នៅថ្ងៃប៉ូលីសចាប់ខ្ញុំ ចាប់មុខឡាក់គីស្តា ព្រោះខ្ញុំរកផ្ទះឱ្យគេ ប៉ូលីសបានស្លៀកពាក់ស៊ីវិល មកហៅខ្ញុំថាទៅប៉ុស្តិ៍។

នាងខ្ញុំសូមបដិសេធ ខ្ញុំមិនដែលនាំឈ្មោះ[redacted] ធីទៀកម៉ាយ ទៅពិនិត្យនៅមន្ទីរពេទ្យម្តងណានោះទេ។

<u>សំណូមពរ:</u> សូមតុលាការជួយរកយុត្តិធម៌ និងដោះលែងខ្ញុំឱ្យមានសេរីភាពឡើងវិញផង។

-បានស្តាប់សាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted] ពៅ នាពេលសវនាការថា៖ នៅ ថ្ងៃកើតហេតុ គឺខ្ញុំមិនបានដឹងរឿងអ្វីទាំងអស់។ ខ្ញុំមិនដែលស្គាល់ឈ្មោ[redacted] ផាង ទេ ខ្ញុំស្គាល់តែឈ្មោ[redacted] ព្រោះរកស៊ីគប់ដេដី និងផ្ទះជាមួយគ្នា។ ខ្ញុំមិនដែលស្គាល់ឈ្មោះ [redacted] ធីទៀកម៉ាយ និងឈ្មោ[redacted] ពៅ ហើយឈ្មោះ ចូវ ក៏មិនស្គាល់ទៀត។

ពេលថ្ងៃកើតហេតុឈ្មោះ [redacted] ធី ទូរស័ព្ទហៅខ្ញុំទៅជួបគ្នានៅឡាក់គីស្តា ដើម្បីរកផ្ទះជួល។ ពេលទៅដល់ប៉ូលីសបានចាប់ខ្លួនខ្ញុំតែម្តង។

នាងខ្ញុំសូមឆ្លើយបដិសេធ ខ្ញុំមិនបាននាំក្មេងស្រីទៅមើលឈាមនោះទេ។

<u>សំណូមពរ:</u> សូមតុលាការជួយរកយុត្តិធម៌ ឱ្យនាងខ្ញុំផង និងសូមឱ្យខ្ញុំបានរួចផុតពីបទចោទ។



Scanned by CamScanner

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក [redacted] ម៉ាច ការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ពៅ នាពេលសវនាការថា៖ នៅក្នុងថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ការចាប់ខ្លួនរបស់កូនក្តីខ្ញុំគឺ នៅមុខសណ្ឋាគារឡាក់គីស្តារ តាមការណាត់របស់ឈ្មោះ [redacted] ធី ដើម្បីរកផ្ទះជួល។

តាំងពីតុលាការថ្នាក់ក្រោម និងសាលាឧទ្ធរណ៍ ក៏កូនក្តីខ្ញុំនៅតែរក្សាចម្លើយ និងការអះអាងនៅដដែលថា ខ្លួនពុំធ្វើការជួញដូរនោះទេ ដូច្នេះរាល់ចម្លើយធ្វើឡើង ដោយមានការបង្ខិតបង្ខំ។ ហេតុដូចនេះកូនក្តីខ្ញុំក៏បានបដិសេធគ្រប់ចម្លើយទាំងអស់។ ទាំងចម្លើយរបស់ជនរងគ្រោះ ក៏មានការបង្ខិតបង្ខំផងដែរ។

កូនក្តីខ្ញុំជាអ្នកគប់ជើង តាំងពីយូរឆ្នាំមកហើយ ការឃាត់ខ្លួន គ្មានភស្តុតាង និងគ្មានសាក្សីឡើយ។ អញ្ចឹងការចោទប្រកាន់នេះ ពុំទាន់មានភស្តុតាងគ្រប់គ្រាន់ក្នុងការដាក់បន្ទុកមកលើកូនក្តីខ្ញុំឡើយ។

ចំពោះជនរងគ្រោះ កូនក្តីខ្ញុំមិនបានស្គាល់ទេ។ ហេតុនេះការជួញដូរកុមារ គឺកូនក្តីខ្ញុំមិនមានការពាក់ព័ន្ធអ្វីឡើយ។ កូនក្តីខ្ញុំនៅតែទទូច និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ សម្រេចជួយរកយុត្តិធម៌ឱ្យបានរួចផុតពីបទចោទ ដោយក្តីអនុគ្រោះផង។

-បានស្តាប់សេចក្តីសន្និដ្ឋានមេធាវីលោក [redacted] សុផល ការពារឱ្យជនជាប់ចោទឈ្មោះ [redacted] ផាង និង [redacted] ពៅ នាពេលសវនាការថា៖ ក្រោយពីបានស្តាប់ដំណាក់ការសួរដេញដោលរួចមកយល់ឃើញថា ក្នុងរឿងនេះ គឺគ្រាន់តែជារឿងប្រហាក់ប្រហែល និងជាការប្រឌិតតែម្តង សូមក្រុមប្រឹក្សាពិចារណា ប្រសិនជួញដូរលក់ដូរផ្លូវភេទ ត្រូវមានអ្នកទិញ-អ្នកលក់។ ដូច្នេះកូនក្តីខ្ញុំក្នុងថ្ងៃកើតហេតុ គឺលក់ប្រហិតតាំងពីព្រលឹមរហូតដល់ម៉ោង១ ហើយកូនក្តីកំពុងហូបបាយ ក៏មានអ្នកមកភូតកុហក ហើយបានដឹកកូនក្តីខ្ញុំទៅក៏បានចាប់ខ្លួនតែម្តង។

ប៉ុន្តែបើពិនិត្យទៅលើអង្គហេតុ និងអង្គច្បាប់ ខ្ញុំសូមបដិសេធ ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌។ យោងតាមមាត្រា៩០ និងមាត្រា១០១ ក្រមនីតិវិធីប្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

មានសាក្សីជាច្រើន ដែលបានឃើញកូនក្តីលក់ប្រហិត និងញុំបាយ គឺឈ្មោះ [redacted] ហុក [redacted] តាំង [redacted] ន , [redacted] សុភាព

បើពិនិត្យទៅចម្លើយទាំងអស់បានឆ្លើយឈ្មោះ [redacted] ផាង គឺបានឆ្លើយនៅគ្រប់នីតិវិធី គឺខ្លួនមិនស្គាល់ឈ្មោះ [redacted] ពៅ ទេ។

ដូច្នេះរាល់ចម្លើយមិនមានភាពស៊ីសង្វាក់គ្នាទេ។ ចំណុចនេះរាល់ចម្លើយមិនមានភាពស៊ីសង្វាក់គ្នាទេ។

ចំណុចនេះខ្ញុំសូមមោឃៈភាពនីតិវិធីនេះតែម្តង ផ្អែកតាមសាលក្រម និងសាលដីការបស់សាលាឧទ្ធរណ៍។ ដូច្នេះអំពើទាំងអស់នេះ គឺកូនក្តីខ្ញុំមិនចូលក្នុងមាត្រា៣៥ ជួញដូររកស៊ីផ្លូវភេទនោះទេ។ ផ្អែកតាមមាត្រា៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>សំណូមពរ:</u> សូមបង្វិលសំណុំរឿងទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះឡើងវិញ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក [redacted] ឡុង ការពារឲ្យជនជាប់ចោទឈ្មោះ [redacted] ធី នាពេលសវនាការថា៖ ការទំនាក់ទំនងរវាងជនជាប់ចោទទាំង៣នាក់ ក្នុងរឿងការអូសទាញពេស្យាចារកុមារ គឺជនជាប់ចោទទាំង៣នាក់ គាត់មិនដែលស្គាល់គ្នា ហើយក៏មិនស៊ីជំរៅគ្នាទៀត។ ចំពោះជនរងគ្រោះ បានឆ្លើយនៅប៉ុស្តិ៍នគរបាលថា៖ ការបង្ខិតបង្ខំរបស់ប៉ូលីសឱ្យឆ្លើយថា ការអូសទាញពេស្យាចារកុមារ។ ដូច្នេះការអូសទាញពេស្យាចារ មានអ្នកលក់ និងអ្នកទិញ។ ជាក់ស្តែងក្នុងថ្ងៃកើតហេតុទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ប៉ូលីសបានចាប់ខ្លួនជនជាប់ចោទ៣នាក់ គឺគ្មានដីកានោះឡើយ ហើយក៏មិនមែនជាបទល្មើសព្រហ្មទណ្ឌជាក់ស្តែងឡើយ។

ការចាប់ខ្លួននៅមុខសណ្ឋាគារឡាក់គីស្តារ ដូច្នេះទង្វើរប៉ូលីស គឺធ្វើគ្រាន់តែមានការសង្ស័យទាំងអស់។

វិក័យប័ត្រពេទ្យ ក៏មិនបានបញ្ជាក់ថាកូនក្តីខ្ញុំ ជាអ្នកនាំក្មេងទៅមន្ទីរពេទ្យនោះដែរ។ យោងតាមមាត្រា៣៨ រដ្ឋធម្មនុញ្ញ និងមាត្រា៣៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដូច្នេះវិមតិសង្ស័យ ត្រូវតែបានជាអត្ថប្រយោជន៍ដល់ជនជាប់ចោទជានិច្ច។

កូនក្តីខ្ញុំមិនបានប្រព្រឹត្តបទល្មើសនេះទេ ដូច្នេះអាចធ្វើការលើកលែងចោទ។ នៅក្នុងសំណុំរឿងទាំងមូល គ្មានហេតុផលថា កូនក្តីខ្ញុំមិនមានពាក់ព័ន្ធក្នុងរឿងនេះសោះឡើយ។

ហើយសាលក្រម និងសាលដីកាសាលាឧទ្ធរណ៍ បានសម្រេចសេចក្តីផ្ទុយ និងច្បាប់យ៉ាងធ្ងន់ធ្ងរ។

<u>សំណូមពរ:</u> សូមក្រុមប្រឹក្សាជំនុំជម្រះ សម្រេច៖

-បដិសេធរបស់សាលាឧទ្ធរណ៍ និងបង្វិលសំណុំរឿង ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីលោក [redacted] សារឿន ការពារឲ្យដើមបណ្តឹងនាពេលសវនាការថា៖ ខ្ញុំបាទសូមសន្និដ្ឋានឱ្យកូនក្តីខ្ញុំតែពីប្រាក់សំណង ព្រោះតុលាការថ្នាក់ក្រោមមិនបានសម្រេចអំពីប្រាក់សំណង មកឱ្យកូនក្តីខ្ញុំនោះឡើយ។ ដូច្នេះការសម្រេចនេះមិនមានលក្ខណៈត្រឹមត្រូវនោះទេ។

សាលក្រម និងសាលដីការបស់សាលាឧទ្ធរណ៍ បានសម្រេចពីពិរុទ្ធភាព ដល់ជនជាប់ចោទចុះហេតុអ្វីមិនសម្រេចអំពីប្រាក់សំណងផង។

<u>សំណូមពរ:</u> សូមក្រុមប្រឹក្សាសម្រេចតាមសំណូមពរ របស់កូនក្តីខ្ញុំដែលមានសារណាចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២ តាមច្បាប់។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ, សេកចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

និងសេចក្ដីសន្និដ្ឋានរបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ០៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២ , លេខ០៩ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២, លេខ ១១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ របស់ជនជាប់ចោទ [redacted] ធី, [redacted] ពៅ , [redacted] ផាង និងបណ្ដឹងសាទុក្ខលេខ ២៤ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ របស់ដើមបណ្ដឹងរដ្ឋប្បវេណី [redacted] ឌីក ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេច តម្កល់សាលក្រមព្រហ្មទណ្ឌរបស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ក្នុងការប្រកាសពិរុទ្ធភាព និងផ្ដន្ទាទោសលើជនជាប់ចោទ [redacted] ផាង, [redacted] ធី និង [redacted] ពៅ ជាការត្រឹមត្រូវហើយ ព្រោះថាទោះបីជាជនជាប់ចោទទាំង៣នាក់នេះបានបដិសេធថា ខ្លួនមិនបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់ក្ដី គឺជនជាប់ចោទទាំង៣នាក់នេះធ្លាប់បានឆ្លើយសារភាពរួចហើយ នៅនគរបាលយុត្តិធម៌ ហើយការសារភាពបានបង្ហាញអង្គហេតុស៊ីសង្វាក់គ្នា ទៅនឹងចម្លើយរបស់ជនរងគ្រោះ [redacted] ពៅ ហៅ ង៉ែត និង [redacted] ធីម៉ាយ ព្រមទាំងមានវេជ្ជបញ្ជាចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ ដែលបានពិនិត្យព្រហ្មចារីជនរងគ្រោះ និងលិខិតពិនិត្យឈាមជនរងគ្រោះ រកវីរុសហ៊ីវ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ របស់គ្លីនិក ចំរុង បញ្ជាក់ថាភស្ដុតាងបន្ថែមទៀតផង។ ដូច្នេះពិតជាមានភស្ដុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនជាប់ចោទ [redacted] ផាង, [redacted] ធី និង [redacted] ពៅ ក្នុងបទចោទប្រកាន់ប្រាកដមែន។ ប៉ុន្ដែការដែលផ្ដន្ទាទោសជនជាប់ចោទ [redacted] ផាង, [redacted] ធី និង [redacted] ពៅ ពីបទៈ អូសទាញពេស្យាចារកុមារ ដោយផ្អែកតាមវាក្យខណ្ឌទី២ នៃមាត្រា៣៥ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនោះ ជាការមិនត្រឹមត្រូវទេ ព្រោះថាវាក្យខណ្ឌទី២ នៃមាត្រា៣៥ នេះសំដៅទៅលើអំពើប្រព្រឹត្តដែលមានលក្ខណៈជាអាជីព ឬជាមុខរបរ ហើយក្នុងកិច្ចស៊ើបសួរករណីនេះ មិនបានរកឃើញភស្ដុតាងណាមួយ បង្ហាញអំពីលក្ខណៈជាអាជីព ឬជាមុខរបរ នោះឡើយ ដូច្នេះគប្បីផ្ដន្ទាទោសតាមវាក្យខណ្ឌទី១ នៃមាត្រានេះវិញ។

-យល់ឃើញថា ដោយជនរងគ្រោះ មិនទាន់បានទទួលរងព្យសនកម្មខាងរូបកាយនៅឡើយនោះ ព្យសនកម្មដែលបណ្ដាលមកពីបទល្មើសព្រហ្មទណ្ឌនេះ គឺមានត្រឹមតែព្យសនកម្មខាងផ្លូវចិត្តប៉ុណ្ណោះ។ ដូច្នេះការដែលតុលាការព្រហ្មទណ្ឌ មិនបានសម្រេចឱ្យមានសំណងរដ្ឋប្បវេណីតាម បណ្ដឹងទាមទារនោះ ជាការមិនត្រឹមត្រូវទេ ព្រោះថាមិនបានអនុវត្តតាមមាត្រា១៣,មាត្រា១៥ និងវាក្យខណ្ឌទី១ នៃមាត្រា២២ ក្រមនីតិវិធីព្រហ្មទណ្ឌទេ។



Scanned by CamScanner

-យល់ឃើញថា វាក្យខណ្ឌទី១ ត្រូវផ្តន្ទាទោសផ្សេងពី វាក្យខណ្ឌទី២ នៃមាត្រា៣៥ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ហើយមិនបានសម្រេចអំពីសំណងរដ្ឋប្បវេណីផងនោះ គប្បីតុលាការកំពូលអនុវត្តតាមវាក្យខណ្ឌចុងក្រោយ នៃមាត្រា៤៤១ ក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០៤"ក្រIIIឃ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈមិនត្រឹមត្រូវទេ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ០៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១២, លេខ០៩ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១២ លេខ១១ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ របស់ជនជាប់ចោទ[redacted]ធី, [redacted]ពៅ, [redacted]ផាង និងបណ្តឹងសាទុក្ខលេខ២៤ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោ[redacted] ឌីក។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ១០៤"ក្រIIIឃ" ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២៨ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍វិញ ដើម្បីជំនុំជម្រះជាថ្មី។

៤-សាលដីកានេះ ជំនុំជម្រះនៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៤។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែ[illegible] ឆ្នាំ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែ[illegible] ឆ្នាំ២០១៤

ជ.ប្រធានតុលាការកំពូល

អនុប្រធាន

[redacted]